# ប្រកាស
# ស្តីពី
# ការទូទាត់សងជាមុននូវប្រាក់ថ្លៃជួលនិងភតិសន្យា

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/ ២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/ ១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០២/ ០៣៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន

## ស ំ រេ ច

**ប្រការ ១ .-**

ធនាគារត្រូវបានអនុញ្ញាតឱ្យទូទាត់សងប្រាក់ថ្លៃជួលឬភតិសន្យាលើទ្រព្យសម្បត្តិ ដោយត្រូវគោរពតាមលក្ខណវិនិច្ឆ័យមួយចំនួនដូចខាងក្រោម ។

**ប្រការ ២ .-**

ទ្រព្យសម្បត្តិដែលបានជួលឬភតិសន្យាត្រូវបំរើឱ្យប្រតិបត្តិការផ្ទាល់របស់ធនាគារ ។ ធនាគារមិនត្រូវបានអនុញ្ញាតឱ្យជួល ប្រសិនបើទ្រព្យសម្បត្តិនោះមិនត្រូវបានប្រើប្រាស់សំរាប់សកម្មភាពចាំបាច់របស់ធនាគារទេ ។

**ប្រការ ៣ .-**

យោងតាមគោលការណ៍នៃខ្លឹមសារមានទម្ងន់លើទំរង់ ការជួលឬភតិសន្យាដែលបានទូទាត់មុន មិនអាចត្រូវបានប្រើសំរាប់ដកប្រាក់ពីធនាគារទេ ហើយជាពិសេស មិនអាចត្រូវបានប្រើសំរាប់ដកដើមទុនផ្ទាល់របស់ភាគទុនិកឡើយ ។

**ប្រការ ៤ .-**

ការជួលឬភតិសន្យាដែលបានទូទាត់មុន មិនត្រូវឱ្យលើសពីរយៈពេលមួយឆ្នាំ នៃថ្លៃជួលទ្រព្យសម្បត្តិឡើយ ។

**ប្រការ ៥ .-**

ប្រសិនបើធនាគារត្រូវតំកល់ប្រាក់ធានាឬត្រូវផ្តល់ឥណទានក្នុងចំនួនណាមួយឱ្យម្ចាស់ទ្រព្យសម្បត្តិ នោះគឺជាចំនួនប្រាក់ដែលបានទូទាត់រួចកត់ត្រានៅក្នុងតារាងតុល្យការ ហើយចំនួនប្រាក់នោះ មិនត្រូវលើសពីមួយឆ្នាំនៃថ្លៃជួលទ្រព្យសម្បត្តិទេ ។

**ប្រការ ៦ .-**

ចំនួនប្រាក់ដែលបានទូទាត់រួចទាំងអស់ លើសពីប្រាក់ថ្លៃជួលទ្រព្យសម្បត្តិមួយឆ្នាំនឹងត្រូវកាត់ចេញពីមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។

**ប្រការ ៧ .-**

ក្នុងករណីប្រាក់ថ្លៃជួលដែលបានទូទាត់ជាមុនលើការជួលឬភតិសន្យា មានរយៈពេលតិចជាងមួយឆ្នាំ ក៏ប៉ុន្តែមានតំលៃខ្ពស់ជាងថ្លៃទីផ្សារ គំលាតរវាងប្រាក់ថ្លៃជួលដែលបានទូទាត់មុនលើការជួលឬភតិសន្យាជាមួយថ្លៃទីផ្សារ នឹងត្រូវបានដកចេញពីមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។

**ប្រការ ៨ .-**

ការជួលឬភតិសន្យាជាមួយសម្ព័ន្ធញាតិ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសស្តីពីការផ្តល់ឥណទានទៅឱ្យសម្ព័ន្ធញាតិ ។ ថ្លៃជួលទ្រព្យសម្បត្តិដែលបានទូទាត់ឱ្យសម្ព័ន្ធញាតិដែលនៅសល់ និងប្រាក់ជួលឬភតិសន្យាដែលទូទាត់មុន នឹងត្រូវបានបញ្ចូលទៅក្នុងប្រតិវេទន៍ប្រចាំត្រីមាសស្តីពីឥណទានដែលបានផ្តល់ឱ្យសម្ព័ន្ធញាតិ ។

**ប្រការ ៩ ៈ**

ធនាគារដែលមានប្រាក់ថ្លៃជួលឬភតិសន្យាដែលបានទូទាត់មុនលើសពី មួយឆ្នាំ នឹងត្រូវបានទុកពេលឱ្យអនុវត្តតាមប្រកាសនេះក្នុងរយៈពេលប្រាំមួយខែ ។ ផុតរយៈពេលនេះ ប្រាក់ថ្លៃជួលឬភតិសន្យាដែលបានទូទាត់មុនលើសពីមួយឆ្នាំ នឹងត្រូវបានកាត់ចេញពីមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។

**ប្រការ ១០ ៈ**

ទោះបីជាមានប្រការទី ៦ និងប្រការទី ៨ ក៏ដោយ ធនាគារដែលមិនអនុវត្តបានតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវទទួលរងការផាកពិន័យតាមមាត្រាទី ៥២នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ១១ ៈ**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋានអង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ១២ ៈ**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែមិនា ឆ្នាំ ២០០៤

**ទេសាភិបាល**

**កន្លែងទទួល**

- ដូចប្រការ ១១ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពតិមាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះក្នុងរាជកិច្ច"